ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃ អ.ស.ប

# ពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ
## អំពីការចូលរួមរបស់កុមារ នៅក្នុងជំលោះប្រដាប់អាវុធ

អនុម័ត និង បើកអោយចុះហត្ថលេខា អោយសច្ចាប័ន និងសុំចូលជាសមាជិក ដោយ
សេចក្តីសំរេចមហាសន្និបាទនៃអង្គការសហប្រជាជាតិលេខ ៖ A/RES/54/263 ចុះថ្ងៃទី ២៥ ឧសភា ឆ្នាំ ២០០០

មិនទាន់ចូលជាធរមាន (សូមមើលមាត្រា១០)

រដ្ឋជាភាគីទាំងឡាយនៃពិធីសារនេះ ៖

 ដោយបានទទួលនូវការលើកទឹកចិត្តដោយសារមានការឧបត្ថម្ភគាំទ្រយ៉ាងច្រើនលើសលប់ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារនោះ បង្ហាញអោយឃើញពីការតាំងចិត្តមោះមុតក្នុងលក្ខណៈរីករាលដាល ដែលកំពុងតែមានមកហើយក្នុងការប្រយុទ្ធតស៊ូដើម្បីលើកស្ទួយ និងការពារសិទ្ធិកុមារ

 ដោយធ្វើការបញ្ជាក់អះអាងសារជាថ្មីឡើងវិញថា សិទ្ធិកុមារ តំរូវអោយមានកិច្ចការពារពិសេស និង ដោយអំពាវនាវអោយមានការធ្វើអោយប្រសើរឡើងអោយជាប់លាប់នូវស្ថានភាពកុមារ ដោយពុំមានការប្រកាន់ បែងចែក ក៏ដូចជាអោយមានការអភិវឌ្ឍន៍ និងការអប់រំបណ្តុះបណ្តាលដល់កុមារ នៅក្នុងលក្ខខ័ណ្ឌសន្តិភាព និងសន្តិសុខ

 ដោយមានការរំខានដោយសារផលប៉ះពាល់នៃជំលោះប្រដាប់អាវុធ ដែលមានលក្ខណៈរីករាលដាល និងនាំអោយខូចខាតចំពោះកុមារ និងដែលមានផលវិបាករយៈពេលយូរ ចំពោះភាពរឹងមាំនៃសន្តិភាព សន្តិសុខ និងការអភិវឌ្ឍន៍

- ដោយថ្កោលទោសចំពោះការតំរង់មុខព្រួញសំដៅកុមារនៅក្នុងស្ថានការណ៍នៃជំលោះប្រដាប់អាវុធ និងការវាយប្រហារដោយផ្ទាល់ទៅលើកម្មវត្ថុទាំងឡាយ ដែលការពារដោយច្បាប់អន្តរជាតិ ដែលរាប់បញ្ចូលទាំងទីកន្លែងនានា ដែលជាទូទៅជាកន្លែង ដែលកុមារតែងតែមានវត្តមានគួរអោយកត់សំគាល់ ដូចជាសាលារៀន និងមន្ទីរពេទ្យជាដើម

 ដោយកត់សំគាល់ឃើញថា នៅក្នុងការអនុម័តនូវលក្ខន្តិកៈក្រុងរ៉ូមស្តីពីការតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ហើយជាពិសេសការចាត់ទុកជាឧក្រិដ្ឋកម្មសង្គ្រាមនូវការកេណ្ឌ ឬចុះបញ្ជីជ្រើសរើសកុមារក្រោមអាយុ ១៥ ឆ្នាំ ឬប្រើប្រាស់កុមារអោយចូលរួមយ៉ាងសកម្មនៅក្នុងអំពើអរិភាពទាំងនៅក្នុងជំម្លោះប្រដាប់អាវុធ ជាលក្ខណៈអន្តរជាតិ និងទាំងមិនមែនជាលក្ខណៈអន្តរជាតិ

- ដោយយល់ឃើញដូច្នេះថា ដើម្បីពង្រឹងបន្ថែមទៀតនូវការអនុវត្តន៍សិទ្ធិទាំងឡាយ ដែលបានទទួលស្គាល់នៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ គឺចាំបាច់ត្រូវបង្កើនការការពារដល់កុមារ ពីការចូលរួមនៅក្នុងជំលោះប្រដាប់អាវុធ

- ដោយកត់សំគាល់ឃើញថា មាត្រា ១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ចែងថា ក្នុងគោលបំណងនៃអនុសញ្ញានេះ កុមារគឺមានន័យថាជនគ្រប់រូបដែលមានអាយុតិចជាងដប់ប្រាំបីឆ្នាំលើកលែងតែអាយុពេញវ័យត្រូវបានគេសន្មត់រហ័សជាងនេះ អាស្រ័យដោយអនុលោមតាមច្បាប់ សំរាប់អនុវត្តចំពោះកុមារ

- ដោយមានជំនឿជឿជាក់ថានៅក្នុងពិធីសារជ្រើសរើសនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ការតម្លើងអាយុដែលអាចជ្រើសអោយចូលបំរើក្នុងកងកំលាំងប្រដាប់អាវុធ និងការចូលរួមរបស់កុមារនៅក្នុងអំពើអរិភាពនឹងរួមចំណែកយ៉ាងមានប្រសិទ្ធិភាពក្នុងការអនុវត្តន៍នូវគោលការណ៍ស្តីពី ការត្រូវយកចិត្តទុកដាក់គិតគូរជាចំបង ពីផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារនៅក្នុងគ្រប់សកម្មភាពទាំងអស់ ដែលទាក់ទងនឹងកុមារ

- ដោយកត់សំគាល់ឃើញថា សន្និសិទអន្តរជាតិលើទី ២៦ នៃកាកបាទក្រហម និងអឌ្ឍច័ន្ទក្រហមកាលពីខែធ្នូ ឆ្នាំ១៩៩៥ បានធ្វើអនុសាសន៍ ក្នុងចំណោមបញ្ហាដ៏ទៃទៀតជាច្រើន ស្នើអោយ ភាគីទាំងឡាយនៅក្នុងជំលោះត្រូវចាត់វិធានការតាមដែលអាចធ្វើទៅបាន ដើម្បីធានាកុំអោយកុមារអាយុក្រោម ១៨ ឆ្នាំ ចូលរួមនៅក្នុងអំពើអរិភាព

- ដោយស្វាគមន៍ ចំពោះការសំរេចអនុម័តជាឯកច្ឆ័ន្ទ កាលពីខែមិថុនា ឆ្នាំ១៩៩៩ ដោយអង្គការពលកម្មអន្តរ ជាតិ (ILO)លើអនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងការចាត់វិធានការជាបន្ទាន់ ដើម្បីលប់បំបាត់ពលកម្មកុមារក្នុងទំរង់ធ្ងន់ធ្ងរបំផុត ដែលក្នុងនោះ បានហាមឃាត់ក្នុងចំណោមបញ្ហាដ៏ទៃទៀតជាច្រើន នូវការជ្រើសរើសកុមារដោយបង្ខំ ដើម្បីប្រើប្រាស់នៅក្នុងជំលោះប្រដាប់អាវុធ

- ដោយថ្កោលទោស ព្រោះមានកង្វល់យ៉ាងខ្លាំងបំផុតពីបញ្ហាការជ្រើសរើស ការហ្វឹកហ្វឺន និងការប្រើប្រាស់កុមារនៅក្នុងទឹកដី ឬឆ្លងកាត់ព្រំដែនរបស់ប្រទេស នៅក្នុងអំពើអរិភាពនានា ដោយក្រុមប្រដាប់អាវុធទាំងឡាយក្រៅពីកងកំលាំងប្រដាប់អាវុធរបស់រដ្ឋ និងដោយទទួលស្គាល់ពីការដែលត្រូវតែទទួលខុសត្រូវរបស់អ្នកទាំងឡាយដែលធ្វើការជ្រើសរើស ហ្វឹកហ្វឺន និងប្រើប្រាស់កុមារនៅក្នុងគោលដៅខាងលើនេះ

- ដោយរំលឹកឡើងវិញពីកាតព្វកិច្ចនៃភាគីនិមួយៗ នៅក្នុងជំលោះប្រដាប់អាវុធ ដែលត្រូវតែគោរពប្រតិបត្តិតាមបទបញ្ញត្តិនៃច្បាប់មនុស្សធម៌អន្តរជាតិ

- ដោយសង្កត់ធ្ងន់ថាពិធីសារនេះ មិនធ្វើអោយប៉ះពាល់ដល់គោលបំណង និងគោលការណ៍ទាំងឡាយ ដែលមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិដែលក្នុងនោះរួមមាន មាត្រា៥១ ផង និងដែលមាននៅក្នុងបទដ្ឋាននានានៃច្បាប់មនុស្សធម៌អន្តរជាតិ ដែលពាក់ព័ន្ធ

- ដោយចងចាំនៅក្នុងចិត្តថា លក្ខខ័ណ្ឌទាំងឡាយនៃសន្តិភាព និងសន្តិសុខដោយផ្អែកលើមូលដ្ឋានការគោរពយ៉ាងពេញលេញនូវគោលបំណង និងគោលការណ៍ទាំងឡាយ ដែលចែងនៅក្នុងធម្មនុញ្ញសហប្រជាជាតិ និងការគោរពតាមឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលកំពុងអនុវត្តជាធរមាន គឺមានសារសំខាន់ណាស់សំរាប់ការពារដល់កុមារ អោយបានយ៉ាងពេញទំហឹង ជាពិសេសនៅក្នុងពេលមានជំលោះប្រដាប់អាវុធ និងក្នុងពេលចូលកាន់កាប់ដោយបរទេស

- ដោយទទួលស្គាល់ថា សេចក្តីត្រូវការពិសេសរបស់កុមារ ដែលងាយទទួលរងគ្រោះជាពិសេស ដោយការជ្រើសរើស ឬប្រើប្រាស់នៅក្នុងអំពើអរិភាព គឺជាការផ្ទុយទៅនឹងពិធីសារនេះ ដោយហេតុមកពី ស្ថានភាពសេដ្ឋកិច្ច ឬឋានៈក្នុងសង្គម ឬភេទរបស់គេ

- ដោយយកចិត្តទុកដាក់គិតគូរពីភាពចាំបាច់ ត្រូវធ្វើការពិនិត្យពិចារណាអំពីមូលហេតុដែលជាឫសគល់ទាក់ទងខាងសេដ្ឋកិច្ច សង្គម និង នយោបាយ នៃការចូលរួមរបស់កុមារនៅក្នុងជំលោះប្រដាប់អាវុធ

- ដោយមានជំនឿជឿជាក់លើភាពចាំបាច់ ត្រូវពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តន៍ពិធីសារនេះ ក៏ដូចជាក្នុងការធ្វើនីតិសម្បទា ខាងផ្នែករាងកាយ និងចិត្តសាស្ត្រ និងការធ្វើសមាហរណកម្មសង្គមនូវ កុមារទាំងឡាយ ដែលរងគ្រោះដោយសារជំលោះប្រដាប់អាវុធ

- ដោយទទួលការលើកទឹកចិត្ត ដោយការចូលរួមរបស់សហគមន៍ ហើយជាពិសេសរបស់កុមារ និងកុមាររងគ្រោះ ក្នុងការផ្សព្វផ្សាយពត៌មាន និងកម្មវិធីអប់រំផ្សេងៗ ទាក់ទងនឹងការអនុវត្តន៍ពិធីសារនេះ

បានព្រមព្រៀងគ្នាដូចតទៅនេះ ៖-

មាត្រា ១-.

រដ្ឋដែលជាភាគីទាំងឡាយ ត្រូវចាត់វាល់វិធានការតាមដែលអាចធ្វើបាន ដើម្បីធានាថាសមាជិកនៃកងកំលាំងប្រដាប់អាវុធរបស់ខ្លួន ដែលអាយុមិនទាន់គ្រប់ ១៨ ឆ្នាំ នៅឡើយ នឹងមិនមានចូលរួមដោយផ្ទាល់នៅក្នុងអំពើអរិភាពផ្សេងៗឡើយ។

មាត្រា ២-.

រដ្ឋដែលជាភាគីទាំងឡាយ ត្រូវធានាថា ជនទាំងឡាយណា ដែលមិនទាន់គ្រប់អាយុ ១៨ ឆ្នាំ នឹងមិនត្រូវជ្រើសរើសក្នុងលក្ខណៈជាកាតព្វកិច្ចអោយចូលក្នុងកងកំលាំងប្រដាប់អាវុធរបស់ខ្លួនឡើយ។

មាត្រា ៣-.

1- រដ្ឋជាភាគីទាំងឡាយ ត្រូវកំណត់តំលើងអាយុអប្បបរិមាសំរាប់ការចូលរួមដោយស្ម័គចិត្ត ក្នុងការជ្រើសរើសមនុស្សចូលបំរើនៅក្នុងកងកំលាំងប្រដាប់អាវុធជាតិរបស់ខ្លួន លើសពីអាយុ ដែលបានចែងនៅក្នុងវាក្យខ័ណ្ឌ ៣ មាត្រា ៣៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដោយផ្អែកតាមគោលការណ៍ទាំងឡាយនៅក្នុងមាត្រានោះ ព្រមទាំងទទួលស្គាល់ថា តាមអនុសញ្ញានេះ ជនទាំងឡាយដែលមានអាយុក្រោម ១៨ ឆ្នាំ មានសិទ្ធិត្រូវទទួលនូវកិច្ចការពារពិសេស។

2- រដ្ឋជាភាគីនិមួយៗ ត្រូវដាក់តំកល់នូវសេចក្តីប្រកាសដែលមានភ្ជាប់កាតព្វកិច្ច បន្ទាប់ពីបានផ្តល់សច្ចាប័ន ឬ ការសុំចូលជាភាគីនៃពិធីសារនេះ ដែលក្នុងនោះចែងកំណត់ពីអាយុអប្បបរិមា ដែលអនុញ្ញាតអោយចូលរួមដោយស្ម័គ្រចិត្តក្នុងការជ្រើសរើសចូលបំរើក្នុងកងកំលាំងប្រដាប់អាវុធជាតិនិងសេចក្តីរៀបរាប់អំពីវិធានការការពារដែលខ្លួនបានសំរេចរៀបចំឡើងដើម្បីធានាកុំអោយមានការបង្ខិតបង្ខំនៅក្នុងការ ជ្រើសរើសនោះ។

3- រដ្ឋជាភាគីទាំងឡាយ ដែលអនុញ្ញាតអោយជ្រើសរើសជនដែលមាន អាយុក្រោម ១៨ ឆ្នាំ ចូលរួមដោយ ស្ម័គ្រចិត្តនៅក្នុងកងកំលាំងប្រដាប់អាវុធជាតិរបស់ខ្លួន ត្រូវប្រកាន់ខ្ជាប់នូវវិធានការការពារ ក្នុងលក្ខណៈជាអប្បរិមាមួយ ដើម្បីធានា ៖-

(ក)- ថាកាជ្រើសរើសនោះ គឺធ្វើក្នុងលក្ខណៈស្ម័គ្រចិត្តពិតប្រាកដមែន ។

(ខ)- ថាការជ្រើសរើសនោះ គឺធ្វើឡើងដោយមានការជូនដំណឹងពីការយល់ព្រមរបស់ឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់ជននោះ។

(គ)- ថាជននោះ ត្រូវបានគេជំរាបអោយដឹងពេញលេញហើយ ពីភារកិច្ចដែលត្រូវធ្វើនៅក្នុងការបំរើកងទ័ពនោះ ។

(ឃ)- ថាជននោះ បានផ្តល់នូវសក្ខីកម្ម ដែលអាចទុកចិត្តបាន ពីអាយុមុនពេលទទួលយល់ព្រមអោយចូលបំរើក្នុងកងទ័ពជាតិ។

4- រដ្ឋជាភាគីនិមួយៗ អាចកែប្រែធ្វើឱ្យប្រសើរឡើងនូវសេចក្តីប្រកាសរបស់ខ្លួនបានគ្រប់វេលាទាំងអស់ដោយការធ្វើជាសេចក្តីជូនដំណឹងមួយអំពីកិច្ចការនេះ រួចធ្វើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ហើយអគ្គលេខាធិការត្រូវជូនដំណឹងបន្តទៅដល់គ្រប់រដ្ឋទាំងអស់ជាភាគី។ សេចក្តីជូនដំណឹងនោះ ត្រូវចូលជាធរមាននាកាលបរិច្ឆេទ ដែលអគ្គលេខាធិការបានទទួលសេចក្តីជូនដំណឹង។

5- សេចក្តីតំរូវអោយមានការកំណត់តំលើងអាយុ ដូចចែងក្នុងកថាខ័ណ្ឌ១នៃមាត្រានេះ មិនត្រូវយកទៅអនុវត្តចំពោះសាលារៀនទាំងឡាយ ដែលដំណើរការ ឬ គ្រប់គ្រង ដោយកងកំលាំងប្រដាប់អាវុធរបស់រដ្ឋភាគីនោះទេ គឺត្រូវអនុលោមតាមមាត្រា ២៨ និង ២៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

មាត្រា ៤ -.

1- បណ្តាក្រុមប្រដាប់អាវុធទាំងឡាយ ដែលផ្សេងពីកងកំលាំងប្រដាប់អាវុធរបស់រដ្ឋមួយ ទោះបីជាស្ថិតនៅក្នុងកាលៈទេសៈណាមួយក៏ដោយ ក៏មិនត្រូវធ្វើការជ្រើសរើស ឬប្រើប្រាស់មនុស្សអាយុក្រោម ១៨ ឆ្នាំ នៅក្នុងអំពើអរិភាពដែរ។

2- រដ្ឋជាភាគីទាំងឡាយត្រូវមានវិធានការតាមដែលអាចធ្វើទៅបាន ដើម្បីទប់ស្កាត់កុំអោយមានការជ្រើសរើស និងប្រើប្រាស់មនុស្សផ្ទុយនឹងកថាខ័ណ្ឌខាងលើនេះ ដោយរួមមានការដាក់ចេញនូវវិធានការខាងផ្លូវច្បាប់តាមចាំបាច់ ដើម្បីហាមឃាត់ និងដាក់ឱ្យទៅជាបទព្រហ្មទ័ណ្ឌចំពោះការអនុវត្តន៍ដូចខាងលើនេះ ។

3- ការអនុវត្តន៍មាត្រានេះនៃពិធិសារ នឹងមិនមានប៉ះពាល់ចំពោះឋានៈតាមផ្លូវច្បាប់នៃភាគីណាមួយនៅក្នុងជំលែ១ះប្រដាប់អាវុធនោះទេ។

មាត្រា ៥-.

នៅក្នុងពិធីសារនេះ មិនមានបទបញ្ញត្តិណាមួយ ត្រូវបានបកស្រាយ យកធ្វើជាការបដិសេធចោលនូវបទបញ្ញត្តិទាំងឡាយនៅ ក្នុងច្បាប់របស់រដ្ឋជាភាគីណាមួយ ឬក្នុងឧបករណ៍អន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិ ដែលនាំអោយការអនុវត្តន៍ សិទ្ធិកុមារបានសំរេចលទ្ធផលល្អប្រសើរជាងនោះទេ ។

មាត្រា ៦-.

1- រដ្ឋជាភាគីនិមួយៗ ត្រូវចាត់រាល់វិធានការចាំបាច់ខាងផ្លូវច្បាប់ ផ្លូវរដ្ឋបាល និងវិធានការដ៏ទៃទៀត ដើម្បីធានាការអនុវត្តន៍ និងការប្រតិបត្តិនូវបទបញ្ញត្តិនៃពិធីសារនេះ ប្រកបដោយប្រសិទ្ធិភាព នៅក្នុងរង្វង់យុត្តាធិការរបស់ខ្លួន។

2- រដ្ឋទាំងឡាយជាភាគី ត្រូវទទួលភារៈក្នុងការធ្វើអោយគោលការណ៍ និងបទបញ្ញត្តិទាំងឡាយនៃពិធិសារនេះបានយល់ជ្រួតជ្រាបយ៉ាងទូលំទូលាយ និងជំរុញលើកស្ទួយតាមមធ្យោបាយសមស្របដល់មនុស្សពេញវ័យ ក៏ដូចជាដល់កុមារ។

3- រដ្ឋជាភាគីទាំងឡាយត្រូវចាត់វិធានការតាមដែលអាចធ្វើទៅបាន ដើម្បីធានាថា ជនទាំងឡាយដែលស្ថិតនៅក្នុងដែនយុត្តាធិការរបស់ខ្លួន ដែលត្រូវបានជ្រើសរើស ឬប្រើប្រាស់នៅក្នុងអំពើអរិភាព ដែលផ្ទុយពីខ្លឹមសារនៃពិធីសារនេះត្រូវបានរំសាយឬក៏ដោះលែងអោយវិលត្រឡប់ពីការបំរើការ។ ក្នុងករណីមានការចាំបាច់ រដ្ឋជាភាគីទាំងឡាយត្រូវផ្តល់ជំនួយឧបត្ថម្ភអោយបានសមស្របដល់អ្នកទាំងនោះ ដើម្បីជួយអោយគេបានជាសះជាទាំងផ្លូវកាយ និងផ្លូវចិត្ត ព្រមទាំងធ្វើសមាហរណកម្មគេអោយចូលរួមរស់ក្នុងសង្គមវិញ។

មាត្រា ៧-.

1- រដ្ឋជាភាគីទាំងឡាយ ត្រូវរួមសហប្រតិបត្តិការគ្នាក្នុងការអនុវត្តន៍ពិធីសារនេះ ក្នុងនោះរួមមាន ការបង្ការសកម្មភាពណាដែលផ្ទុយនឹងពិធីសារនេះ និង ការស្តារនីតិសម្បទា ព្រមទាំងការធ្វើសមាហរណកម្មអោយចូលមកក្នុងសង្គមវិញ នូវជនទាំងឡាយដែលរងគ្រោះដោយសារអំពើដែលផ្ទុយនឹងពិធីសារនេះ ដែលរួមមានតាមរយៈសហប្រតិបត្តិការបច្ចេកទេសនិងជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ។ ជំនួយឧបត្ថម្ភ និងសហប្រតិបត្តិការ ត្រូវធ្វើឡើងដោយមានការពិគ្រោះ យោបល់ជាមួយរដ្ឋជាសាម៉ីភាគី និងអង្គការអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធ។

2- រដ្ឋជាភាគីទាំងឡាយក្នុងតួនាទី ត្រូវធ្វើដូចខាងលើនេះ ត្រូវផ្ដល់ជំនួយឧបត្ថម្ភតាមរយៈកម្មវិធីទ្វេភាគី ពហុភាគី ឬកម្មវិធីផ្សេងទៀត ដែលមានស្រាប់ ឬក្នុងចំណោមជំនួយដ៏ទៃទៀត តាមរយៈមូលនិធិស្ម័គ្រចិត្ត ដែលបង្កើតឡើងស្របតាមវិធាននៃមហាសន្និបាតអង្គការសហប្រជាជាតិ។

មាត្រា ៨-.

1- រដ្ឋជាភាគីនិមួយ ៗ នៅក្នុងរយៈពេល ២ ឆ្នាំ បន្ទាប់ពីពិធីសារនេះចូលជាធរមាន សំរាប់រដ្ឋជាសមាជិកនោះ ត្រូវដាក់ជូនគណៈកម្មាធិការស្ដីពីសិទ្ធិកុមារ នូវរបាយការណ៍មួយផ្ដល់ពត៌មានយ៉ាងល្អិតល្អន់ស្ដីពីវិធានការដែលខ្លួនបានចាត់តាំងអនុវត្តនូវបទបញ្ញត្តិនៃពិធីសារនេះ រួមទាំងវិធានការ ដែលបានចាត់ដើម្បីអនុវត្តនូវបទបញ្ញត្តិ ស្ដីពីការចូលរួម និងការជ្រើសរើស ។

2- បន្ទាប់ពីការដាក់ជូននូវរបាយការណ៍លំអិត រដ្ឋជាភាគីនិមួយៗ ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ ដែលខ្លួនដាក់ជូនគណៈកម្មាធិការស្ដីពីសិទ្ធិកុមារ នូវពត៏មានបន្ថែមទៀតក្រៅពីនេះ ដែលទាក់ទងទៅនឹងការអនុវត្តិពិធីសារ អនុលោមទៅតាម មាត្រា៤៤ នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។ រដ្ឋជាភាគីដ៏ទៃទៀតនៃពិធីសារត្រូវដាក់ជូនរបាយការណ៍ ប្រាំឆ្នាំម្ដង ។

3- គណៈកម្មាធិការស្ដីពីសិទ្ធិកុមារអាចស្នើអោយរដ្ឋជាភាគីទាំងឡាយផ្ដល់នូវពត៏មានបន្ថែមទៀតបាន ទាក់ទងនឹងការអនុវត្តន៍ពិធីសារនេះ ។

មាត្រា ៩ -.

1- ពិធីសារនេះ បើកចំហឱ្យរដ្ឋភាគីនៃអនុសញ្ញា ឬរដ្ឋដែលបានចុះហត្ថលេខាលើអនុសញ្ញា ចុះហត្ថលេខា ។

2- ពិធីសារនេះ គឺជាកម្មវត្ថុនៃការផ្ដល់សច្ចាប័ន និងបើកឱ្យមានការសុំចូលជាសមាជិក ពីសំណាក់រដ្ឋណាមួយក៏បាន។ ឧបករណ៍សំរាប់ការផ្ដល់សច្ចាប័ន ឬការសុំចូលជាសមាជិក ត្រូវដាក់ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីតំកល់ ។

3- អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្នុងឋានៈជាអ្នកដំកល់ទុកនូវអនុសញ្ញា និងពិធីសារ ត្រូវជូនដំណឹងដល់រដ្ឋជាភាគីទាំងអស់នៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាពីឧបករណ៍នៃសេចក្ដីប្រកាសដោយអនុលោមទៅតាមមាត្រា ១៣ ។

មាត្រា ១០-.

១-ពិធីសារនេះត្រូវចូលជាធរមានបីខែបន្ទាប់ពីការដាក់ដំកល់ឧបករណ៍ទី១០នៃការផ្ដល់សច្ចាប័នឬការសុំចូលជាសមាជិក។

២-ក្រោយពីពិធីសារចូលជាធរមានចំពោះរដ្ឋដែលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិកនៃពិធីសារនេះ ពិធីសារនឹងចូលជាធរមានចំពោះរដ្ឋទាំងនោះ ក្នុងរយៈពេលមួយខែក្រោយពីកាលបរិច្ឆេតដែលរដ្ឋទាំងឡាយនោះតំកល់ឧបករណ៍នៃការផ្ដល់សច្ចាប័នឬការសុំចូលជាសមាជិកនៃពិធីសាររបស់ខ្លួន។

មាត្រា ១១-.

១- រដ្ឋជាភាគីណាមួយក៏ដោយ អាចប្រកាសបដិសេធលែងចូលរួមជាភាគីនៃពិធីសារនេះបានគ្រប់ពេលវេលាទាំងអស់ ដោយការធ្វើសេចក្តីជូនដំណឹងជាលាយលក្ខអក្សរមួយ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលបន្ទាប់ពីនេះ អគ្គលេខាធិការត្រូវជូនដំណឹងដល់រដ្ឋជាភាគីដ៏ទៃទៀតនៃអនុសញ្ញា និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញា។ ការប្រកាសបដិសេធលែងចូលរួម នឹងចូលជាធរមាននៅក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹង ដោយអគ្គលេខាធិការ ។ ប៉ុន្តែ បើសិនជាក្នុងពេលដែលត្រូវផុតកំណត់ នៃឆ្នាំនោះ ស្រាប់តែរដ្ឋជាភាគីដែលប្រកាសបដិសេធលែងចូលរួម ចូលរួមក្នុងជំលោះប្រដាប់អាវុធ នោះ សេចក្តីប្រកាសបដិសេធមិនមានប្រសិទ្ធិភាពទេ លុះត្រាតែជំលោះប្រដាប់អាវុធចប់សិន។

២- សេចក្តីប្រកាសបដិសេធដូចនេះ ពុំមានអានុភាពធ្វើអោយរដ្ឋជាភាគីរួចចាកផុតពីកាតព្វកិច្ច របស់ខ្លួនដែលស្ថិតនៅក្រោមពីធីសារនេះបានទេ ចំពោះអំពើណាមួយ ដែលកើតមានឡើងមុនកាលបរិច្ឆេទ ដែលសេចក្តីប្រកាសបដិសេធចាប់ផ្តើមមានប្រសិទ្ធិភាព ហើយក៏មិនអាចអោយរដ្ឋជាភាគីណាមួយរួចចាកផុតផងដែរ បើសេចក្តីប្រកាសបដិសេធនោះ ធ្វើអោយខូចខាតបែបណាមួយដល់ ការពិនិត្យពិចារណាបន្តទៅទៀតលើបញ្ហាអ្វីមួយដែលបានដាក់ជូនគណៈកម្មាធិការរួចហើយៗ ដែលកំពុងស្ថិតក្នុងការពិចារណា តាំងពីមុនកាលបរិច្ឆេទ ដែលសេចក្តីប្រកាសនេះ មានប្រសិទ្ធិភាព។

មាត្រា ១២ -.

១- រដ្ឋជាភាគីណាមួយក៏ដោយ អាចលើកសំណើសុំធ្វើវិសោធនកម្ម(ពិធីសារ) ដោយដាក់សំណើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ បន្ទាប់ពីបានទទួលសំណើធ្វើវិសោធនកម្ម អគ្គលេខាធិការ ត្រូវជូនដំណឹងអំពីសំណើនោះដល់រដ្ឋជាភាគីទាំងឡាយ ដោយសុំអោយរដ្ឋទាំងនោះមានមតិបញ្ជាក់ថា តើគេឯកភាពក្នុងការបើកធ្វើសន្និសិទមួយនៃរដ្ឋជាភាគីដើម្បីនឹងពិចារណានិងបោះឆ្នោតអនុម័តលើសំណើសុំធ្វើវិសោធនកម្មនោះ ដែរឬ ទេ ។ ក្នុងករណីដែលក្នុងរយៈពេលយ៉ាងយូរបួនខែបន្ទាប់ពីថ្ងៃជូនដំណឹង មានរដ្ឋជាភាគីចំនួន ១/៣ យ៉ាងតិច គាំទ្រអោយបើកធ្វើសន្និសិទនោះ អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវកោះអញ្ជើញចូលរួមសន្និសិទ ដែលស្ថិតក្រោមការជួយឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ វិសោធនកម្មណាមួយ ដែលអនុម័តដោយសំលេងភាគច្រើននៃរដ្ឋជាភាគីដែលបានចូលរួម និងបោះឆ្នោតអនុម័តនៅក្នុងពេលធ្វើសន្និសិទ្ធិ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិដើម្បីអនុម័តយល់ព្រម។

២- វិសោធនកម្ម ដែលបានអនុម័តស្របតាមកថាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវចូលជាធរមានបន្ទាប់ពីបានទទួលការអនុម័តយល់ព្រម ដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងឯកភាពដោយសំលេងភាគច្រើន ២/៣នៃរដ្ឋជា សមាជិក។

៣-នៅពេលដែលវិសោធនកម្មចូលជាធរមាន រដ្ឋភាគីដែលបានអនុម័តយល់ព្រម ត្រូវជាប់កាតព្វកិច្ចគោរពតាមវិសោធនកម្មនោះ ហើយរដ្ឋជាភាគីដ៏ទៃទៀតក៏នៅតែត្រូវជាប់កាតព្វកិច្ចគោរពតាមបទបញ្ញត្តិបច្ចុប្បន្ន នៃពិធីសារនេះ ព្រមទាំងរាល់វិសោធនកម្មទាំងឡាយពីមុនមក ដែលខ្លួនបានអនុម័តយល់ព្រម។

មាត្រា ១៣-.

១- ពិធីសារនេះ ដែលមានអត្ថបទជាភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល ដែលមានតំលៃតាមច្បាប់ស្មើគ្នា ត្រូវយកទៅដាក់ដំកល់នៅក្នុងប័ណ្ណសារនៃអង្គការសហប្រជាជាតិ។

២-អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនច្បាប់ចំលងនៃពិធីសារនេះ ដោយមានសេចក្តី បញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម ដល់គ្រប់រដ្ឋជាភាគីទាំងអស់នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ព្រមទាំងគ្រប់រដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

□ ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃ អ.ស.ប

ពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ

# អំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

អនុម័ត និង បើកអោយចុះហត្ថលេខា អោយសច្ចាប័ន និងសុំចូលជាសមាជិក ដោយ
សេចក្តីសំរេចមហាសន្និបាទនៃអង្គការសហប្រជាជាតិលេខ ៖ A/RES/54/263 ចុះថ្ងៃទី ២៥ ឧសភា ឆ្នាំ ២០០០

**មិនទាន់ចូលជាធរមាន (សូមមើលមាត្រា១៤)**

រដ្ឋទាំងឡាយជាភាគីនៃពិធីសារនេះ

- ដោយយល់ឃើញថា ដើម្បីនឹងសំរេចអោយបានជាងនេះទៀត នូវគោលបំណងទាំងឡាយនៃអនុសញ្ញាស្តីពីសិទ្ធិ កុមារ និងដើម្បីអនុវត្តនូវបទបញ្ញត្តិនៃអនុសញ្ញនេះ ជាពិសេសមាត្រា ១, ១១, ២១, ៣២, ៣៣, ៣៤, ៣៥, និង ៣៦ ជាការល្អគួរតែបង្កើនថែមទៀតនូវវិធានការ ដែលរដ្ឋភាគីទាំងឡាយ គប្បីប្រកាន់យកក្នុងការធានាអះអាងការពារកុមារអោយរួចចាកផុតពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

- ដោយយល់ឃើញទៀតថា អនុសញ្ញាស្តីពីសិទ្ធិកុមារបានទទួលស្គាល់សិទ្ធិរបស់កុមារ ដែលត្រូវតែទទួលការការពារអោយរួចផុតពីការកេងប្រវ័ញ្ចន៍ខាងសេដ្ឋកិច្ច និងពីការអោយបំពេញការងារណាមួយដែលអាចគ្រោះថ្នាក់ ឬ ដែលប៉ះពាល់ដល់ការសិក្សាអប់រំរបស់កុមារ ឬ ធ្វើអោយខូចដល់សុខភាព ឬដល់ការអភិវឌ្ឍន៍ផ្នែករាងកាយ ប្រាជ្ញាស្មារតី សីលធម៌ ឬផ្នែកសង្គមរបស់កុមារ

- ដោយមានកង្វល់យ៉ាងខ្លាំងក្លាចំពោះការជួញដូរកុមារជាលក្ខណៈអន្តរជាតិដែលមានលក្ខណៈគួរអោយកត់សំគាល់ និង ដែលចេះតែកើនឡើងក្នុងគោលបំណងដើម្បីយកកុមារទៅជួញដូរ យកទៅធ្វើពេស្យាចារ និង ដើម្បីផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

- ដោយមានការបារម្ភយ៉ាងជ្រាលជ្រៅពីការរីករាលដាល និងចេះតែបន្តទៅទៀតនូវការអនុវត្តន៍ទេសចរណ៍ផ្លូវភេទ ដែលក្នុងនោះ កុមារងាយនឹងត្រូវទទួលរងគ្រោះជាពិសេស ព្រោះការអនុវត្តន៍ខាងលើនេះវាជំរុញដោយផ្ទាល់អោយមានការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ

-ដោយទទួលស្គាល់ថា ក្រុមដែលងាយរងគ្រោះជាពិសេសក្នុងចំនួនដ៏ច្រើន ក្នុងនោះរួមមានកុមារីត្រូវប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារការកេងប្រវ័ញ្ចន៍ផ្លូវភេទខ្លាំងជាងគេ ហើយកុមារីមានចំនួនមិនសមាមាត្រគ្នានៅក្នុងចំណោមអ្នកដែលត្រូវគេកេងប្រវ័ញ្ចផ្លូវភេទ

- ដោយមានការខ្វល់ខ្វាយពីការរីកធំធាត់ក្នុងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារយ៉ាងសម្បូរបែបនៅក្នុងប្រព័ន្ធអ៊ីនធ័រនែត (Internet) និងនៅក្នុងបច្ចេកវិទ្យាផ្សេងៗទៀត ដែលវិវត្តថ្មី ហើយដោយរំលឹកឡើងវិញអំពីសន្និសិទអន្តរជាតិស្តីពី ការប្រយុទ្ធប្រឆាំងនឹងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ នៅក្នុងប្រពន្ធ័អ៊ីនធ័រនែត ( Internet) (នាទីក្រុងវីយែន កាលពីឆ្នាំ ១៩៩៩) ហើយជាពិសេស សេចក្តីសន្និដ្ឋានរួមរបស់សន្និសិទ ដែលអំពាវនាវដល់ពិភពលោកទាំងមូលអោយដាក់ទៅជាបទព្រហ្មទ័ណ្ឌ ចំពោះការផលិត ការចែកចាយ ការនាំចេញ ការផ្ទេរបញ្ជូន ការនាំចូល ការកាន់កាប់ដោយចេតនា និងការផ្សាយពាណិជ្ជកម្មនូវរូបភាពអាសអាភាសកុមារ ហើយដែលសង្កត់ធ្ងន់ពីសារសំខាន់នៃសហប្រតិបត្តិការជិតស្និទ្ធជាងមុន និង ភាពជានៃគូរ រវាងរដ្ឋាភិបាលនានា និងឧស្សាហកម្មអ៊ីនធ័រនែត (Internet Industry)

- ដោយមានជំនឿជឿជាក់ថា ការលប់បំបាត់ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ នឹងត្រូវបានបង្កឱ្យមានលក្ខណៈងាយស្រួលដោយការអនុម័តនូវវិធានការចំរុះមួយដែលដោះស្រាយកត្តាដែលរួមចំណែកនានា ដែលក្នុងនោះរួមមាន ភាពមិនរីកលូតលាស់ ភាពក្រីក្រ គម្លាតគ្នាយ៉ាងខ្លាំងអំពីស្ថានភាពសេដ្ឋកិច្ច ភាពមិនមានសមធម៏នៃរចនាសម្ព័ន្ធផ្នែកសេដ្ឋកិច្ច-សង្គម ភាពមិនដំណើរការនៃគ្រួសារ ភាពខ្វះការសិក្សាអប់រំ ប្រវេសន្តរ៍វាងទីក្រុងនិងជនបទ ការប្រកាន់រើសអើងអំពីភេទ អាកប្បកិរិយាខាងផ្លូវភេទនៃមនុស្សពេញវ័យដែលមិនមានការទទួលខុសត្រូវ ការអនុវត្តន៍ទាំងឡាយតាមទំនៀមទម្លាប់ដែលមានផលអាក្រក់ ជម្លោះប្រដាប់អាវុធ និង ការជួញដូរកុមារ

- ដោយមានជំនឿជឿជាក់ថា ការខិតខំប្រឹងប្រែងក្នុងការធ្វើអោយមានការយល់ដឹង ដល់សាធារណៈជនជាទូទៅ គឺត្រូវការជាចាំបាច់ ដើម្បីនឹងកាត់បន្ថយនូវសេចក្តីត្រូវការរបស់អ្នកប្រើប្រាស់នូវការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ហើយព្រមទាំងមានជំនឿជឿជាក់ផងដែរ លើសារប្រយោជន៍នៃការពង្រឹងភាពជាដៃគូរទូទាំងពិភពលោករវាងតួអង្គទាំងអស់ និងការធ្វើអោយកាន់តែប្រសើរឡើងក្នុងការពង្រឹងការប្រតិបត្តិច្បាប់នៅថ្នាក់ជាតិ

- ដោយកត់សំគាល់អំពីបទបញ្ញត្តិនៃឧបករណ៍អន្តរជាតិផ្នែកច្បាប់ដែលទាក់ទងនឹងការការពារកុមារ រាប់បញ្ចូលទាំងអនុសញ្ញានៃទីក្រុងឡាអេ (Hague) ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អនុសញ្ញានៃទីក្រុងឡាអេ (Hague) ស្តីពីទិដ្ឋភាពផ្នែករដ្ឋប្បវេណីយ នៃការចាប់ពង្រត់កុមារជា លក្ខណៈអន្តរជាតិ អនុសញ្ញានៃទីក្រុងឡាអេ (Hague) ស្តីពីយុត្តាធិការច្បាប់ដែលត្រូវអនុវត្ត ការទទួលស្គាល់ ការអនុវត្តន៍ និងសហប្រតិបត្តិការ លើបញ្ហាការទទួលខុសត្រូវរបស់ឪពុកម្តាយ និង វិធានការផ្សេងៗសំរាប់ការពារកុមារ ព្រមទាំង អនុសញ្ញាលេខ ១៨២ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីការហាមឃាត់ និង វិធានការជាបន្ទាន់ ដើម្បីលុបបំបាត់ពលកម្មកុមារក្នុងទំរង់ទំរង់ធ្ងន់ធ្ងរ

- ដោយមានការលើកទឹកចិត្ត ដោយសារមានការគាំទ្រដ៏ច្រើនលើសលប់ចំពោះអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលសបញ្ជាក់អោយឃើញនូវការប្តេជ្ញាចិត្តយ៉ាងផុសផុលដែលកំពុងមានក្នុងការលើកស្ទួយ និងការពារសិទ្ធិកុមារ

- ដោយទទួលស្គាល់សារៈប្រយោជន៍នៃការអនុវត្តន៍នូវបទបញ្ញត្តិនៃកម្មវិធីសកម្មភាពដើម្បីបង្ការទប់ស្កាត់ការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និង ការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ និង សេចក្តីប្រកាស និង ផែនការសកម្មភាព ដែលបានអនុម័តនៅក្នុងពេលសមាជពិភពលោកប្រឆាំងនឹងការធ្វើពាណិជ្ជកម្មកេងប្រវ័ញ្ចន៍ផ្លូវភេទលើកុមារ ដែលប្រព្រឹត្តទៅនៅ ទីក្រុង ស្តុុកខុម ពីថ្ងៃទី ២៧ ដល់ ៣១ សីហា ឆ្នាំ ១៩៩៦ ព្រមទាំងសេចក្តីសំរេច និងអនុសាសន៍ផ្សេងទៀតនៃស្ថាប័នអន្តរជាតិ ដែលពាក់ព័ន្ធ

- ដោយគិតគូរពិចារណា យ៉ាងត្រឹមត្រូវពីសារៈសំខាន់នៃប្រពៃណី និងតម្លៃខាងវប្បធម៌នៃមនុស្សម្នាក់ៗ ក្នុង ការការពារ និងការអភិវឌ្ឍន៍ប្រកបដោយភាពស៊ីសង្វាក់នៃកុមារ

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ ៖

មាត្រា ១-.

រដ្ឋជាភាគីទាំងឡាយត្រូវហាមឃាត់កុំអោយមានការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ដូចដែលមានចែងនៅក្នុងពិធីសារនេះ ។

មាត្រា ២-.

តាមគោលបំណងនៃពិធីសារនេះ ៖

(ក)- ការជួញដូរកុមារ បានន័យថា ជាអំពើ ឬកិច្ចការជំនួញណាមួយ ដែលតាមរយៈនោះ កុមារ ត្រូវបានផ្ទេរបញ្ជូន ដោយមនុស្សណាម្នាក់ ឬមួយក្រុម ទៅអោយមនុស្សម្នាក់ ឬមួយក្រុមទៀត ដើម្បីទូទាត់យកជាប្រាក់ ឬជាថ្នូរអ្វីមួយផ្សេងទៀត ។

(ខ)- ការធ្វើពេស្យាកម្មកុមារ មានន័យថា ការប្រើប្រាស់កុមារនៅក្នុងសកម្មភាពខាងផ្លូវភេទ ដើម្បីទូទាត់យក ជាប្រាក់ ឬជាថ្នូរក្នុងទំរង់បែបណាមួយផ្សេងទៀតក៏ដោយ។

(គ)-ការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ មានន័យថា ការធ្វើអ្វីមួយជាតំណាង ទោះជាតាមមធ្យោបាយអ្វីមួយក៏ដោយ នៃកុមារដែលចូលរួមក្នុងសកម្មភាពខាងផ្លូវភេទ ដោយជាក់ស្តែង ឬ ដោយការធ្វើអោយ ដូចជាជាក់ស្តែង ឬ ការធ្វើអ្វីមួយជាតំណាងណាមួយផ្សេងនៃផ្នែកផ្សេងៗនៃអវយវៈភេទរបស់កុមារ ដើម្បីគោល
បំណងខាង ផ្លូវភេទជាសំខាន់បំផុត ។

មាត្រា ៣-.

១- រដ្ឋជាភាគីនិមួយៗ ត្រូវធានាជាអប្បបរិមាថា អំពើ និងសកម្មភាពទាំងឡាយដូចតទៅនេះ ត្រូវបានចែងគ្របដណ្តប់សព្វគ្រប់អស់ហើយនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ទោះបីជាបទល្មើសទាំងនោះត្រូវបានប្រព្រឹត្តនៅក្នុង ស្រុក ឬឆ្លងប្រទេស ឬដោយបុគ្គល ឬដោយមានការរៀបចំក្តី ៖-

(ក)- នៅក្នុងបរិបទនៃការជួញដូរកុមារដូចមានចែងនៅក្នុងមាត្រា ២ ៖

(i)-ការអោយ ប្រគល់ ឬទទួលយកកុមារ ទោះបីតាមមធ្យោបាយណាមួយក្តី ដើម្បីគោលបំណង ៖

ក- កេងប្រវ័ញ្ចផ្លូវភេទលើកុមារ

ខ- ធ្វើការផ្ទេរសរីរាង្គរបស់កុមារដើម្បីបានកំរៃ

គ- អោយកុមារចូលរួមធ្វើការងារដោយបង្ខំ

(ii)- អន្ទងលួងលោមដោយមិនត្រឹមត្រូវ ក្នុងនាមជាអន្តរការី ដើម្បីទទួលបានការយល់ព្រម ក្នុងការអោយកូនទៅគេសុំយកទៅចិញ្ចឹម ដោយបំពានទៅនឹងឧបករណ៍នានានៃច្បាប់អន្តរជាតិស្តីពីសុំកូនដែលកំពុងស្ថិតនៅជាធរមាន។

(ខ)-ការផ្តល់អោយ ការទទួលយក ការផ្គត់ផ្គង់ ឬ ការផ្តល់កុមារ អោយគេយកទៅធ្វើពេស្យាកម្មកុមារ ដូចមានចែងក្នុងមាត្រា ២

(គ)- ការផលិត ការចែកចាយ ការផ្សព្វផ្សាយ ការនាំចូល ការនាំចេញ ការអោយ ការលក់ ឬការកាន់កាប់ ដើម្បីគោលបំណងដូចខាងលើនូវរូបភាពអាសអាភាសកុមារដូចចែងនៅក្នុងមាត្រា ២

(២)- បទបញ្ញត្តិនៃច្បាប់ជាតិរបស់រដ្ឋភាគី ត្រូវតែយកទៅអនុវត្តដើម្បីផ្តន្ទាទោស ចំពោះករណីប៉ុនប៉ងក្នុងការប្រព្រឹត្តអំពើណាមួយក្នុងចំណោមអំពើទាំងនេះ និង ចំពោះការសមគំនិត ឬការចូលរួម ក្នុងការប្រព្រឹត្តអំពើណាមួយនៃអំពើទាំងនេះ។

(៣)- រដ្ឋជាភាគីនិមួយៗ ត្រូវធ្វើអោយមានការផ្តន្ទាទោសចំពោះបទល្មើសទាំងនេះ អោយស្របទៅតាមទោសបញ្ញត្តិដោយគិតផ្អែកទៅតាមប្រភេទនៃទំងន់ទោស។

(៤)- ដោយអាស្រ័យលើបទបញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន រដ្ឋជាភាគីនិមួយៗត្រូវចាត់វិធានការ ក្នុងករណីសមស្រប ដើម្បីរៀបចំធ្វើ អោយនីតិបុគ្គលទទួលខុសត្រូវតាមច្បាប់ចំពោះបទល្មើសដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះ។ ដោយផ្អែកតាមគោលការណ៍ច្បាប់នៃរដ្ឋជាសមាជិក ការទទួលខុសត្រូវតាមច្បាប់របស់នីតិបុគ្គលអាចជាបទព្រហ្មទ័ណ្ឌ រដ្ឋប្បវេណីយ ឬ រដ្ឋបាល។

(៥)- រដ្ឋជាភាគីទាំងឡាយត្រូវចាត់រាល់វិធានការចាំបាច់ខាងផ្លូវច្បាប់ និងរដ្ឋបាល ដើម្បីធានាអោយជនគ្រប់រូបដែលពាក់ព័ន្ធក្នុងការសុំកូនទៅចិញ្ចឹម អនុវត្តស្របទៅតាមឧបករណ៍នៃច្បាប់អន្តរជាតិជាធរមាន។

មាត្រា ៤-.

១- រដ្ឋជាភាគីនិមួយៗ ត្រូវចាត់វិធានការតាមចាំបាច់ ដើម្បីរៀបចំបង្កើតយុត្តាធិការរបស់ខ្លួនសំរាប់អនុវត្តច្បាប់ចំពោះបទល្មើសដូចមានចែងនៅក្នុង មាត្រា៣ កថាខ័ណ្ឌ១ នៅពេលដែលមានការប្រព្រឹត្តិបទល្មើសលើទឹកដីរបស់ខ្លួន ឬនៅលើនាវា ឬយន្តហោះ ដែលចុះបញ្ជីនៅក្នុងរដ្ឋនោះ។

២- រដ្ឋជាភាគីនិមួយៗ អាចចាត់វិធានការដូចនេះបាន តាមការចាំបាច់ ដើម្បីរៀបចំបង្កើតយុត្តាធិការរបស់ខ្លួនដើម្បីអនុវត្តច្បាប់ចំពោះបទល្មើសដូចមានចែងនៅក្នុងមាត្រា ៣ កថាខ័ណ្ឌ ១ នៅក្នុងករណីដូចតទៅនេះ ៖-

(ក)-នៅពេលជនដែលត្រូវចោទប្រកាន់ ជាជនជាតិរបស់រដ្ឋនោះ ឬ ជាជនដែលមានទីលំនៅជាប្រក្រតី នៅលើទឹកដីរបស់ខ្លួន

(ខ)- នៅពេលជនរងគ្រោះជាជនជាតិរបស់រដ្ឋនោះ ។

៣-រដ្ឋជាភាគីនិមួយៗក៏ត្រូវចាត់វិធានការដូចនេះ តាមចាំបាច់ផងដែរ ដើម្បីរៀបចំបង្កើតយុត្តាធិការរបស់ខ្លួនដើម្បីអនុវត្តចំពោះបទល្មើសដូចបញ្ជាក់ខាងលើ បើសិនជនល្មើសដែលត្រូវចោទប្រកាន់មានវត្តមាននៅលើទឹកដីរបស់ខ្លួន ហើយដែលខ្លួនមិនធ្វើបត្យាប័នទៅអោយរដ្ឋជាភាគីមួយផ្សេងទៀតឈរលើមូលដ្ឋានបទល្មើសប្រព្រឹត្តឡើងដោយជនជាតិកំណើតណាម្នាក់របស់រដ្ឋនោះ ។

៥- ពិធីសារនេះ មិនបដិសេធយុត្តាធិការផ្នែកព្រហ្មទ័ណ្ឌណាមួយដែលអនុវត្តអនុលោមតាមច្បាប់ក្នុងស្រុកនោះទេ។

មាត្រា ៥-.

១-បទល្មើសដូចមានចែងនៅក្នុង មាត្រា ៣ កថាខ័ណ្ឌ១ ត្រូវចាត់ទុកថា ត្រូវបានរាប់បញ្ចូលជាបទល្មើស

ដែលអាចធ្វើបត្យាប័នបាន ក្រោមសន្ធិសញ្ញាស្ដីពីបត្យាប័នណាមួយដែលមានស្រាប់ រវាងរដ្ឋជាភាគី និង ត្រូវបានរាប់បញ្ចូលជាបទល្មើសដែលអាចធ្វើបត្យាប័នបាន ក្រោមរាល់សន្ធិសញ្ញាស្ដីពីបត្យាប័នដែល បានព្រមព្រៀងក្រោយៗ មកទៀតរវាងរដ្ឋជាភាគីទាំងនោះ ដោយស្របទៅតាមលក្ខខ័ណ្ឌ ដែលចែងកំណត់នៅក្នុង សន្ធិសញ្ញាទាំងនោះ។

២-បើសិនជារដ្ឋជាភាគីមួយ ដាក់លក្ខខ័ណ្ឌក្នុងការធ្វើបត្យាប័ន ដោយផ្អែកតាមអត្ថិភាពនៃសន្ធិសញ្ញាណាមួយដែលមានស្រាប់ ទទួលការស្នើសុំអោយធ្វើបត្យាប័នពីរដ្ឋមួយផ្សេងទៀត ដែលខ្លួនមិនមានធ្វើសន្ធិសញ្ញាស្ដីពីបត្យាប័នជាមួយ រដ្ឋជាភាគីនោះ អាចចាត់ទុកពិធីសារនេះជាមូលដ្ឋានផ្នែកច្បាប់ ដើម្បីនឹងធ្វើបត្យាប័នចំពោះបទល្មើសទាំងនោះបាន។ ការធ្វើបត្យាប័ន ត្រូវអនុវត្តតាមលក្ខខ័ណ្ឌនានា ដែលចែងនៅក្នុងច្បាប់របស់រដ្ឋដែលត្រូវស្នើសុំ។

៣-រដ្ឋជាភាគីទាំងឡាយ ដែលមិនដាក់លក្ខខ័ណ្ឌក្នុងការធ្វើបត្យាប័ន ទៅលើអត្ថិភាពនៃសន្ធិសញ្ញាណាមួយ ត្រូវទទួលស្គាល់ថា បទល្មើសទាំងនោះជាបទល្មើសដែលអាចធ្វើបត្យាប័នបានរវាងរដ្ឋជាភាគីទាំងនោះ ដោយអនុវត្តទៅតាមលក្ខខ័ណ្ឌដែលច្បាប់របស់រដ្ឋដែលត្រូវស្នើសុំនោះបានចែង។

៤- សំរាប់គោលបំណងនៃការធ្វើបត្យាប័នរវាងរដ្ឋទាំងឡាយជាភាគី បទល្មើសទាំងនោះត្រូវចាត់ទុកដូចជាត្រូវបានប្រព្រឹត្តឡើងមិនត្រឹមតែនៅកន្លែង ដែលបទល្មើសនោះកើតឡើងប៉ុណ្ណោះទេ ក៏ប៉ុន្តែនៅក្នុងទឹកដីនៃរដ្ឋទាំងឡាយដែលតំរូវឱ្យបង្កើតយុត្តាធិការស្របតាមមាត្រា ៤ ទៀតផង។

៥- បើសិនជាការស្នើសុំធ្វើបត្យាប័ន ត្រូវបានធ្វើឡើងចំពោះបទល្មើសដូចបានរៀបរាប់នៅក្នុងមាត្រា ៣ កឋាខ័ណ្ឌ ១ ហើយបើសិនជារដ្ឋជាភាគី ដែលត្រូវគេស្នើសុំនោះ មិនព្រមធ្វើបត្យាប័ន ឬនឹងមិនធ្វើបត្យាប័នទេ ដោយផ្អែកលើមូលហេតុសញ្ជាតិរបស់ជនល្មើស រដ្ឋនោះត្រូវចាត់វិធានការសមស្រប ដើម្បីបញ្ជូនករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋជាភាគីនោះ ដើម្បីធ្វើការចោទប្រកាន់។

មាត្រា ៦-.

១- រដ្ឋជាភាគីទាំងឡាយ ត្រូវលៃលកដោះស្រាយជួយឧបត្ថម្ភគ្នាទៅវិញទៅមក ក្នុងការចាត់វិធានការក្នុងទ្រង់ទ្រាយធំទាក់ទងទៅនឹងការស៊ើបអង្កេត ឬ ដំណើការក្ដីរឿងព្រហ្មទ័ណ្ឌ ឬ ដំណើរការធ្វើបត្យាប័ននានាដែលត្រូវធ្វើឡើងពាក់ព័ន្ធនឹងបទល្មើសទាំងឡាយដូចមានចែងក្នុង មាត្រា ៣ កឋាខ័ណ្ឌ ១ ក្នុងនោះរួមមានជួយឧបត្ថម្ភក្នុងការស្វែងរកភស្ដុតាង ក្រោមការចាត់ចែងរបស់រដ្ឋជាភាគីទាំងនោះ តាមការចាំបាច់ សំរាប់ជួយដល់ដំណើរការក្ដី។

២- រដ្ឋជាភាគីទាំងឡាយ ត្រូវអនុវត្តកាតព្វកិច្ចរបស់ខ្លួនដូចចែងនៅក្នុង កឋាខ័ណ្ឌ ១ នៃមាត្រានេះ អនុលោមតាមសន្ធិសញ្ញាណាមួយ ឬការសំរបសំរួលគ្នាដ៏ទៃទៀតស្ដីពីការជួយឧបត្ថម្ភផ្នែកច្បាប់ទៅវិញទៅមក ដែលអាចធ្វើឡើងរវាងរដ្ឋជាភាគីទាំងនោះ។ បើសិនជាមិនមានសន្ធិសញ្ញា ឬការសំរបសំរួលដូចខាងលើទេនោះ រដ្ឋជាភាគីទាំងឡាយត្រូវជួយដោះស្រាយឧបត្ថម្ភគ្នាទៅវិញទៅមកដោយអនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន។

មាត្រា ៧-.

រដ្ឋជាភាគីទាំងឡាយ ដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់ជាតិរបស់ខ្លួន ត្រូវ ៖-

(ក) ចាត់វិធានការសមស្របដើម្បីជួយក្នុងការឃាត់ទុក ឬរឹបអូសនូវ ៖-

(i) ទំនិញ ដូចជាសំភារៈ ទ្រព្យសម្បត្តិ និងគ្រឿងសំភារៈដ៏ទៃទៀត ដែលបានប្រើប្រាស់ក្នុងការប្រព្រឹត្តិ ឬការសំរួលដល់ការប្រព្រឹត្តិបទល្មើស ក្រោមពិធីសារនេះ

(ii) ប្រាក់កំរៃ ដែលបានមកពីបទល្មើសទាំងនោះ

(ខ) អនុវត្តតាមការស្នើសុំពីរដ្ឋជាភាគីណាមួយផ្សេងទៀត ក្នុងការឃាត់ទុក ឬរឹបអូសនូវទំនិញ ឬប្រាក់កំរៃ ដូចដែលបានចែងនៅក្នុងវាក្យខ័ណ្ឌ (ក) (i) និង ( i i ) ខាងលើ

(គ) ចាត់វិធានការផ្សេងៗ ដើម្បីអោយបិទទ្វារជាបណ្តោះអាសន្ន ឬជាស្ថាពរ នូវទីតាំងទាំងឡាយ ដែលត្រូវបានប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស។

មាត្រា ៨-.

១-រដ្ឋជាភាគីទាំងឡាយត្រូវដាក់ចេញនូវវិធានការសមស្រប ដើម្បីការពារសិទ្ធី និងផលប្រយោជន៍ របស់កុមាររងគ្រោះ ដោយសារការអនុវត្តន៍ទាំងឡាយដែលត្រូវបានហាមឃាត់ដោយពិធីសារនេះ នៅក្នុងគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទ័ណ្ឌជាពិសេសដោយ ៖-

(ក)ទទួលស្គាល់ពីភាពងាយទទួលរងគ្រោះនៃកុមាររងគ្រោះ និង ដោយកែច្នៃនីតិវិធី ដើម្បីទទួលស្គាល់សេចក្តីត្រូវការពិសេសរបស់កុមាររងគ្រោះ រួមបញ្ចូលទាំងសេចក្តីត្រូវការជាពិសេសរបស់គេក្នុងការធ្វើជាសាក្សី

(ខ) ដោយប្រាប់ដល់កុមាររងគ្រោះពីសិទ្ធិ តួនាទីរបស់គេ និងវិសាលភាព កាលវិភាគ និងការវិវត្តន៍នៃដំណើរការក្តី និងនៃការសំរេចសេចក្តីចំពោះករណីរបស់គេ

(គ) ដោយអនុញ្ញាតអោយកុមាររងគ្រោះបញ្ចេញនូវទស្សនៈ សេចក្តីត្រូវការ និង កង្វល់របស់គេ ដើម្បីបង្ហាញ និង សំរាប់អោយធ្វើការពិចារណានៅក្នុងពេលដំណើរការក្តីលើករណីរឿងដែលមានផលប៉ះពាល់ចំពោះផលប្រយោជន៍បុគ្គលរបស់កុមារ ដោយស្របទៅតាមវិធាននៃនីតិវិធីនៃច្បាប់ជាតិ ។

(ឃ)- ដោយផ្តល់សេវាគាំទ្រសមស្របចំពោះកុមារដែលរងគ្រោះ នៅក្នុងដំណើរការក្តីតាមផ្លូវច្បាប់ទាំងមូល។

(ង)- ដោយការពារដោយសមស្របចំពោះសិទ្ធិឯកជន និងអត្តសញ្ញាណនៃកុមាររងគ្រោះ ព្រមទាំងចាត់វិធានការផ្សេងៗ ស្របតាមច្បាប់ជាតិ ដើម្បីជៀសវាងផ្សព្វផ្សាយពត៌មានដោយមិនត្រឹមត្រូវ ដែលអាចបណ្តាលអោយគេស្គាល់អត្តសញ្ញាណរបស់កុមាររងគ្រោះ។

(ច)- ក្នុងករណីសមស្របជួយផ្តល់ការការពារសុវត្ថិភាពដល់កុមាររងគ្រោះ ក៏ដូចជាដល់ក្រុមគ្រួសាររបស់គេ ព្រមទាំងដល់អ្នកធ្វើសាក្សីអោយគេ អោយបានជៀសផុតពីការបំភិតបំភ័យ និងការសងសឹក។

(ឆ)- ដោយជៀសវាងកុំអោយមានការអូសបន្លាយ ដោយមិនចាំបាច់ ក្នុងការសំរេចសេចក្តីលើរឿងក្តី និងក្នុងការអនុវត្តន៍នូវដីកា ឬសេចក្តីសំរេច ដែលបង្គាប់ឱ្យចេញសំណងដល់កុមាររងគ្រោះ។

២- រដ្ឋជាភាគីទាំងឡាយត្រូវតែធានាថាភាពមិនប្រាកដប្រជានៃអាយុពិតប្រាកដរបស់ជនរងគ្រោះ មិនអាចទប់ស្កាត់មិនអោយមានការផ្តួចផ្តើមគំនិតក្នុងការស៊ើបអង្កេតព្រហ្មទ័ណ្ឌបានឡើយ ក្នុងនោះរួមមានទាំងការស៊ើបអង្កេតដើម្បីកំណត់អាយុរបស់ជនរងគ្រោះផង។

៣- រដ្ឋជាភាគីទាំងឡាយ ត្រូវធានាថា ក្នុងការដោះស្រាយតាមប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទ័ណ្ឌដល់កុមារ ដែលរងគ្រោះដោយបទល្មើសដូចបានរៀបរាប់ក្នុងពិធីសារនេះគឺត្រូវគិតគូរជាចំបងដល់ផលប្រយោជន៍ដ៏ល្អបំផុតដល់កុមារ។

៤- រដ្ឋជាភាគីទាំងឡាយ ត្រូវចាត់វិធានការ ដើម្បីធានាអោយមានការហ្វឹកហ្វឺនត្រឹមត្រូវ ជាពិសេសការហ្វឹកហ្វឺនផ្នែកច្បាប់ និងផ្នែកចិត្តសាស្ត្រដល់ជនទាំងឡាយដែលធ្វើការជាមួយជនរងគ្រោះដោយសារបទល្មើសទាំងឡាយដែលត្រូវហាមឃាត់នៅក្នុងពិធីសារនេះ ។

៥- រដ្ឋជាភាគីទាំងឡាយ ក្នុងករណីសមស្រប ត្រូវដាក់ចេញនូវវិធានការផ្សេងៗ ប្រយោជន៍ដើម្បីការពារសុវត្ថិភាព និងបូរណភាពនៃជនទាំងឡាយ និង(ឬ)នៃអង្គការទាំងឡាយដែលពាក់ព័ន្ធក្នុងការបង្ការ និង(ឬ) ក្នុងការការពារ និងស្តារនីតិសម្បទាជនដែលរងគ្រោះដោយសារបទល្មើសដូចនេះ ។

៦- នៅក្នុងមាត្រានេះ គ្មានបញ្ញត្តិណាដែលបកស្រាយថា ជាការធ្វើអោយខូចប្រយោជន៍ ឬមិនស្របជាមួយសិទ្ធិរបស់ជនជាប់ចោទដែលត្រូវតែទទួលការជំនុំជំរះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងមិនលំអៀងនោះទេ។

មាត្រា ៩-.

១- រដ្ឋជាភាគីទាំងឡាយត្រូវអនុម័ត ឬពង្រឹង អនុវត្ត និង ផ្សព្វផ្សាយច្បាប់ វិធានការរដ្ឋបាលគោលនយោបាយសង្គមនិងកម្មវិធីផ្សេងៗដើម្បីបង្ការទប់ស្កាត់បទល្មើសទាំងឡាយដែលមានចែងនៅក្នុងពិធីសារនេះ។ ត្រូវផ្តល់ការយកចិត្តទុក ដាក់ជាពិសេសក្នុងការការពារដល់កុមារដែលងាយរងគ្រោះ ដោយសារការអនុវត្តន៍ទាំងនេះ។

២- រដ្ឋជាភាគីទាំងឡាយ ត្រូវជំរុញឱ្យមានការយល់ដឹងដល់សាធារណៈជនអោយបានទូលំទូលាយ រួមទាំងដល់កុមារ តាមរយៈការផ្សព្វផ្សាយពត៌មាន តាមគ្រប់មធ្យោបាយដែលសមស្រប តាមការអប់រំ និងការបណ្តុះបណ្តាលស្តីពីវិធានការដើម្បីទប់ស្កាត់ និងផលប៉ះពាល់នៃបទល្មើសទាំងឡាយ ដែលបានលើកឡើងនៅក្នុងពិធីសារ។ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមមាត្រានេះ រដ្ឋជាភាគីទាំងឡាយត្រូវលើកទឹកចិត្តអោយមានការចូលរួមរបស់សហគមន៍និកជាពិសេសរបស់កុមារ និងកុមាររងគ្រោះ ក្នុងការផ្សព្វផ្សាយពត៌មាន និងក្នុងកម្មវិធីអប់រំ និងបណ្តុះបណ្តាលរួមបញ្ចូលទាំងថ្នាក់អន្តរជាតិផង។

៣- រដ្ឋជាភាគីទាំងឡាយត្រូវចាត់គ្រប់វិធានការ ដែលអាចធ្វើបាន ក្នុងគោលបំណងធានាអោយមានការជួយឧបត្ថម្ភសមស្របគ្រប់យ៉ាងដល់កុមារដែលរងគ្រោះដោយសារបទល្មើសទាំងនោះ រាប់បញ្ចូលទាំងការធ្វើសមាហរ័ណកម្មពួកគេទៅក្នុងសង្គមវិញដោយពេញលេញ និង ការធ្វើអោយមានលំនឹងទាំងស្រុង ទាំងខាងរូបរាងកាយ និងខាងស្មារតី។

៤- រដ្ឋជាភាគីទាំងឡាយត្រូវធានាថា រាល់កុមារដែលរងគ្រោះទាំងអស់ដោយសារបទល្មើសផ្សេងៗ ដូចដែលមានចែងនៅក្នុងពិធីសារនេះ មានសិទ្ធិក្នុងការប្រើប្រាស់នូវនីតិវិធីផ្សេងៗយ៉ាងគ្រប់គ្រាន់ ក្នុងការទាមទារសំណងជម្ងឺចិត្ត ពីជនទាំងឡាយ ដែលជាអ្នកត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយពុំមានការរើសអើងអ្វីទាំងអស់។

៥- រដ្ឋជាភាគីទាំងឡាយ ត្រូវចាត់វិធានការសមស្របសំដៅធ្វើការហាមឃាត់ប្រកបដោយប្រសិទ្ធិភាពនូវការផលិត និង ការផ្សព្វផ្សាយ នូវសម្ភារៈដែលផ្សព្វផ្សាយបទល្មើសចែងក្នុងពិធីសារនេះ។

មាត្រា ១០-.

១- រដ្ឋជាភាគីទាំងឡាយ ត្រូវចាត់រាល់វិធានការចាំបាច់ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាលក្ខណៈសំរបសំរួលគ្នាជាពហុភាគី តំបន់ និងជាទ្វេភាគី ដើម្បីបង្ការទប់ស្កាត់ ស្វែងរក ស៊ើបអង្កេត ចោទប្រកាន់ និងផ្តន្ទាទោសចំពោះជនដែលទទួលខុសត្រូវចំពោះអំពើទាំងឡាយ ដែលពាក់ព័ន្ធនឹងការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និង ការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ និង ទេសចរណ៍ផ្លូវភេទលើកុមារ ។ រដ្ឋជាភាគីទាំងឡាយត្រូវជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិ និងកិច្ចសំរបសំរួលផងដែរ ជាមួយអាជ្ញាធររបស់ខ្លួន អង្គការក្រៅ រដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងអង្គការអន្តរជាតិនានា។

២- រដ្ឋជាភាគីទាំងឡាយ ត្រូវបង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីជួយឧបត្ថម្ភដល់កុមាររងគ្រោះក្នុងការធ្វើឱ្យមានលំនឹង ខាងផ្នែករូបរាងកាយ និង ខាងស្មារតី ការធ្វើសមាហរ័ណកម្មសង្គម និងការធ្វើមាតុភូមិនិវត្តន៍។

៣-រដ្ឋជាភាគីទាំងឡាយត្រូវជំរុញការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយមូលហេតុទាំងឡាយ ដែលជាឫសគល់ ដូចជាភាពក្រីក្រ និងភាពមិនមានការអភិវឌ្ឍន៍ ដើម្បីរួមវិភាគទានដល់ភាពងាយរងគ្រោះរបស់កុមារដោយសារការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ រូបភាពអាសអាភាសកុមារ និង ទេសចរណ៍ផ្លូវភេទលើកុមារ។

៤- រដ្ឋជាភាគីទាំងឡាយ ក្នុងការត្រៀមលក្ខណៈដើម្បីអនុវត្តតាមដូចខ្លឹមសារខាងលើនេះ ត្រូវផ្តល់ជំនួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ បច្ចេកទេស ឬ ជំនួយឧបត្ថម្ភផ្សេងទៀត តាមរយៈកម្មវិធីពហុភាគី តំបន់ ទ្វេភាគី ឬកម្មវិធីដ៏ទៃទៀតដែលមានស្រាប់។

មាត្រា ១១-.

នៅក្នុងពិធីសារនេះ មិនមានចែងពីអ្វីដែលប៉ះពាល់ដល់បញ្ញត្តិណាមួយ ដែលជំរុញលើកស្ទួយអោយសំរេចលទ្ធផលល្អប្រសើរជាងដល់សិទ្ធិកុមារ ហើយ ដែលអាចមានចែងក្នុង ៖

(ក)- ច្បាប់របស់រដ្ឋជាភាគីណាមួយ ។

(ខ)- ច្បាប់អន្តរជាតិដែលកំពុងស្ថិតនៅជាធរមានសំរាប់រដ្ឋនោះ។

មាត្រា ១២ -.

១-រដ្ឋជាភាគីនិមួយៗ ក្នុងរយៈពេលពីរឆ្នាំ បន្ទាប់ពីពិធីសារនេះចូលជាធរមានចំពោះខ្លួន ត្រូវផ្ញើរបាយការណ៍ជូនគណៈកម្មការស្តីពីសិទ្ធិកុមារ ដោយផ្តល់ពត៌មានល្អិតល្អន់ស្តីពីវិធានការនានាដែលខ្លួនបានចាត់ ក្នុងការអនុវត្តន៍តាមបទបញ្ញត្តិនៃពិធីសារនេះ។

២- បន្ទាប់ពីការដាក់ជូននូវរបាយការណ៍លំអិត រដ្ឋជាភាគីនិមួយៗ ត្រូវដាក់បញ្ចូលនៅក្នុងរបាយការណ៍ ដែលខ្លួនដាក់ជូនគណៈកម្មាធិការស្តីពីសិទ្ធិកុមារនូវពត៌មានបន្ថែមទៀត ដែលទាក់ទងនឹងការអនុវត្តន៍ពិធីសារនេះ អនុលោមតាម មាត្រា៤៤ នៃអនុសញ្ញា ។ ចំណែកឯរដ្ឋជាភាគីឯទៀតនៃពិធីសារនេះត្រូវធ្វើរបាយការណ៍ដាក់ជូននៅរាល់ប្រាំឆ្នាំម្តង។

៣- គណៈកម្មាធិការស្តីពីសិទ្ធិកុមារ អាចស្នើសុំអោយរដ្ឋជាភាគីទាំងឡាយផ្តល់នូវពត៌មានបន្ថែម ទាក់ទងនឹងការអនុវត្តន៍ពិធីសារនេះបាន។

មាត្រា ១៣-.

១- ពិធីសារនេះ បើកចំហអោយរដ្ឋណាមួយក៏ដោយ ដែលជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ចុះហត្ថលេខា។

២-ពិធីសារនេះជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន និង បើកអោយសុំចូលជាសមាជិកពីសំណាក់រដ្ឋណាមួយជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ឬ ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ ឧបករណ៍នៃការផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិក ត្រូវតំកល់ទុកនៅ អគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ។

មាត្រា ១៤-.

1- ពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេល ៣ ខែ បន្ទាប់ពីការដាក់ដំកល់ ឧបករណ៍ផ្តល់សច្ចាប័ន ឬ ការសុំចូលជាសមាជិក ទី ១០ ។

២-ចំពោះរដ្ឋនិមួយៗ ដែលផ្តល់សច្ចាប័ន ឬ សុំចូលជាសមាជិកពិធីសារនេះ នៅក្រោយពេលដែលពិធីសារនេះចូលជាធរមាន នោះពិធីសារនេះ ត្រូវចូលជាធរមានក្នុងរយៈពេលមួយខែ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់តំកល់ឧបករណ៍ផ្តល់សច្ចាប័ន ឬការសុំចូលជាសមាជិក ។

មាត្រា ១៥-.

១- រដ្ឋជាភាគីណាមួយក៏ដោយអាចប្រកាសបដិសេធលែងចូលរួមក្នុងពិធីសារនេះបាន នៅគ្រប់ពេលវេលាទាំងអស់ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ជូនអគ្គលេខាធិការអង្គការសហប្រជាជាតិដែលអគ្គលេខាធិការបន្ទាប់ពីនេះ ត្រូវជូនដំណឹងដល់រដ្ឋជាភាគីនានាដ៏ទៃទៀតនៃអនុសញ្ញា និង ដល់គ្រប់រដ្ឋទាំងអស់ ដែលបានចុះហត្ថលេខាលើអនុសញ្ញា។ ការប្រកាសបដិសេធលែងចូលរួមត្រូវចូលជាធរមាន ក្នុងរយៈពេលមួយឆ្នាំបន្ទាប់ពីកាលបរិច្ឆេទនៃការទទួលសេចក្តីជូនដំណឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២- ការប្រកាសបដិសេធលែងចូលរួមដូចនោះ មិនមានប្រសិទ្ធិភាពអោយរដ្ឋជាភាគីរួចផុតពីកាតព្វកិច្ចរបស់ខ្លួននៅក្រោមពិធីសារនេះបានទេ ពាក់ព័ន្ធទៅនឹងបទល្មើសណាមួយ ដែលកើតឡើងនៅមុនកាលបរិច្ឆេទដែលការប្រកាសបដិសេធនេះចូលជាធរមាន ។ ដូចគ្នានេះដែរ ការប្រកាសបដិសេធនេះ មិនត្រូវធ្វើអោយខូចខាតតាមបែបណាមួយ ដល់ការបន្តពិនិត្យពិចារណាលើបញ្ហាអ្វីមួយ ដែលបានដាក់ជូនគណៈកម្មាធិការស្តីពីសិទ្ធិរួចហើយដើម្បីពិនិត្យពិចារណានៅមុនកាលបរិច្ឆេទ ដែលសេចក្តីប្រកាសបដិសេធនេះចូលជាធរមាន។

មាត្រា ១៦-.

១- រដ្ឋជាភាគីណាមួយក៏ដោយ អាចស្នើសុំធ្វើវិសោធនកម្មបាន ដោយដាក់សំណើនោះជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ បន្ទាប់ពីបានទទួលសំណើធ្វើវិសោធនកម្មនេះ ត្រូវជូនដំណឹងទៅរដ្ឋជាភាគីទាំងអស់ ដោយស្នើអោយរដ្ឋទាំងនេះ មានយោបល់បញ្ជាក់ថា តើរដ្ឋជាភាគី ទាំងឡាយនោះគាំទ្រអោយមានការបើកសន្និសិទ ដើម្បីពិនិត្យពិចារណា និងបោះឆ្នោតអនុម័តលើសំណើសុំធ្វើ វិសោធនកម្មនោះដែរឬទេ ។ ក្នុងករណីប្រសិនបើ នៅក្នុងរយៈពេលបួនខែ គិតចាប់តាំងពីកាលបរិច្ឆេទនៃ ការជូនដំណឹងនោះ មានរដ្ឋជាភាគីចំនួនយ៉ាងតិចមួយភាគបី (១/៣) គាំទ្រអោយមានការបើកធ្វើ សន្និសិទមួយនោះ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវរៀបចំកោះអញ្ជើញធ្វើសន្និសិទ្ធមួយ ក្រោមការឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ។ ការធ្វើវិសោធនកម្មណាមួយ ដែលបានអនុម័តរួចដោយមតិភាគច្រើន នៃរដ្ឋជាភាគីដែលមានវត្តមាន និងដែលបានបោះឆ្នោតនៅក្នុងពេលសន្និសិទ ត្រូវដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ដើម្បីអនុម័តយល់ព្រម។

២- វិសោធនកម្ម ដែលបានអនុម័តស្របតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ត្រូវចូលជាធរមាននៅក្រោយពេលដែលបានការឯកភាពពីមហាសន្និបាតអង្គការសហប្រជាជាតិ និងទទួលការយល់ព្រមដោយមតិភាគច្រើន ២/៣ នៃរដ្ឋជាភាគី។

៣- នៅពេលវិសោធនកម្មណាមួយចូលជាធរមានហើយនោះ រដ្ឋជាភាគីទាំងឡាយ ដែលបានផ្តល់ការយល់ព្រមលើការធ្វើវិសោធនកម្មនេះ ត្រូវជាប់កាតព្វកិច្ចប្រតិបត្តិតាម រីឯរដ្ឋដែលជាភាគីផ្សេងទៀត ត្រូវបន្តគោរពប្រតិបត្តិតាម បទបញ្ញត្តិនៃពិធីសារនេះ ព្រមទាំងវិសោធនកម្មទាំងឡាយពីមុនមកដែលខ្លួនបានយល់ព្រម។

មាត្រា ១៧-.

១- ពិធីសារនេះ ដែលមានអត្ថបទជាភាសា អារ៉ាប់, ចិន, អង់គ្លេស, បារាំង, រុស្ស៊ី និងអេស្ប៉ាញ៉ុល ដែលមានតំលៃតាមច្បាប់ស្មើគ្នា ត្រូវដំកល់នៅក្នុងប័ណ្ណសារនៃអង្គការសហប្រជាជាតិ។

2- អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចំលងនៃពិធីសារនេះ ដោយមានការបញ្ជាក់ត្រឹមត្រូវ ទៅអោយគ្រប់រដ្ឋជាភាគីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងរដ្ឋទាំងអស់ដែលបានចុះហត្ថលេខាលើអនុសញ្ញានេះ ។